គំរោងអេកូសន

ECOSORN PROJECT

# ការចិញ្ចឹមកូននិងមេមាន់



គំរោងស្តារឡើងវិញលើវិស័យសេដ្ឋកិច្ច និង សង្គមកិច្ចនៅបណ្តាខេត្តនៃតំបន់ពាយ័ព្យ

Economic and Social Re-launch of Northwest Provinces (ECOSORN)

បានទទួលការណែនាំពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

Agricultural Development Denmark Asia


អាសយដ្ឋានៈ ភូមិកំពង់ស្វាយឃុំកំពុងស្វាយ

ស្រុកសិរីសោភ័ណខេត្ត បន្ទាយមានជ័យ ។

ទូរស័ព្ទលេខៈ ០១៧ ៤៨៩ ១៥៨

E-mail: sovannaouk@yahoo.com


## ១_លក្ខណៈទូទៅ

ការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារមានសារៈសំខាន់ខ្លាំងណាស់ដល់កសិករជាពិសេសគ្រួសារក្រីក្រនៅតាមជនបទ។ វាទាមទារទុនតិចតែផ្តល់ផលឆាប់ (៤ទៅ៦ខែ) ដែលឆ្លើយតបទៅនឹងតំរូវការផ្សេងៗដូចជា ស៊ុតសាច់ព្រមទាំងប្រាក់ចំណូលគ្រួសារ។ លាមកមាន់ប្រើជាជីសរីរាង្គដ៏មានប្រសិទ្ធភាពសំរាប់ដំណាំផ្សេងៗ។

## ២. ការជ្រើសរើសពូជ



ពូជមាន់មានពីរបែប គឺពូជនាំចូល និងពូជក្នុងស្រុក។

- **ពូជបរទេសៈ** មិនសូវធន់ជំងឺទេប៉ុន្តែឱ្យផលច្រើនមានពង និងសាច់ច្រើនធំធាត់ឆាប់រហ័ស។ តែត្រូវការបច្ចេកទេសថែទាំអនាម័យទ្រុង និងចំណីគ្រប់គ្រាន់។
- **ពូជក្នុងស្រុកៈ** ងាយចិញ្ចឹមជាលក្ខណៈគ្រួសារធន់នឹងជំងឺ មានរស់ជាតិឆ្ងាញ់ចិញ្ចឹមលែងឱ្យវារកចំនីដោយខ្លួនឯង។ ប៉ុន្តែធំធាត់លូតលាស់យឺត និងផ្តល់ទិន្នផលទាប ។
- **ការជ្រើសរើសកូនមាន់មកចិញ្ចឹមៈ** មានសុខភាពល្អរហ័សរហួន ចំពុះបិទឈរត្រង់ ភ្នែកថ្លា និងគ្មានអាចម៍រាក។
- **ការជ្រើសរើសមេមាន់មកចិញ្ចឹមៈ** ត្រូវមានចំពុះបិទជិត ភ្នែកថ្លា សេរក្រហម គូទទូលាយ និងមានពងច្រើន ។

## ៣. ការរៀបចំទ្រូង

- **ទ្រុងសំរាប់មាន់ជំទង់**



- ទ្រុងត្រូវសង់លើដីទួលមិនលេចទឹក និងមានពន្លឺចាំងចូលនៅពេលព្រឹកដើម្បីសំលាប់មេរោគបានមួយចំនួន។
- ដំបូលត្រូវឱ្យ ខ្ពស់សំរូលអោយមានខ្យល់ចេញចូលបានល្អ។
- មានសំបុកគ្រប់គ្រាន់សំរាប់មេមាន់ពង។
- មុននឹងដាក់មាន់ក្នុងទ្រុងត្រូវធ្វើការរំងាប់មេរោគដោយប្រើកំបោរសបាចលើផ្ទៃដីទ្រុងទាំងមូល។
- ទំហំទ្រុងគឺ១ ម៉ែត្រក្រឡាសំរាប់មាន់ ៣ក្បាល។

**ចំណាំៈ** មិនគួរចិញ្ចឹមមាន់ដាក់ក្រោមផ្ទះទេពីព្រោះវាមានឥទ្ធិពលមិនល្អដែលប៉ះពាល់ដល់សុខភាពរបស់មនុស្ស។

- **ទ្រុងចិញ្ចឹមកូនមាន់**

- ទ្រុងត្រូវស្ងួត ស្អាត និងមានពន្លឺចេញចូលគ្រប់គ្រាន់។
- សីតុណ្ហភាពក្នុងទ្រុងសមស្របពី ៣០-៣១ អង្សាសេ មានរបាំងការពារខ្យល់មិនអោយត្រជាក់ពេក។
- របាំងត្រូវមានកំពស់ ១.២០ម-១.៨០ម មានព្រួលឬលួសសំណាញ់បាំងជុំវិញការពារកុំឱ្យសត្វដំទៃចូលស៊ីកូនមាន់។
- កូនមាន់អាយុ ៥-៦ សប្តាហ៍ត្រូវបំបែកទៅចិញ្ចឹមនៅទ្រុងមាន់ជំទង់។
- ទ្រុងកូនមាន់គួរសង់ទៅតាមទំរង់ដែលអាចចល័តបានដើម្បីងាយស្រួលក្នុងការធ្វើអនាម័យ។

## ៤. លក្ខណៈទូទៅនៃការថែទាំ

- **សំបុក:** គេច្រើនប្រើល្អីកញ្ជើរ ឬកន្ត្រកធ្វើជាសំបុក។ ក្នុងល្អីកញ្ជើរ ឬកន្ត្រកគេដាក់ចំបើងស្លឹកចេកស្ងួតជាដើម។ ហើយយកទៅដាក់កន្លែងដែលមានការបិទបាំងល្អមិនសូវមានពន្លឺ។
- **ការថែរទាំកូនមាន់:** មេមាន់បណ្តើរកូនរបស់វាទៅតាមសំបុកនីមួយៗក្នុងកំឡុងអាទិត្យទី ១-៣ ហើយតំរូវការដំបូងរបស់កូនមាន់គឺទឹកស្អាត។ នៅពេលកូនមាន់មានអាយុ ២-៣ខែ មេមាន់ឈប់បណ្តើរកូន រួចពងបន្តទៅទៀត។

## ៥. ចំនី

- **ការរៀបចំចំណីនិងផ្តល់ចំណី:** ការរៀបចំចំណីត្រូវអនុវត្តទៅតាមរបៀបចិញ្ចឹមតាមបែបសេរី ឬតាមការចិញ្ចឹមដាក់ទ្រុង ឬតាមការដាក់ទ្រុងផងលែងផង។ ចំពោះមាន់ដែលចិញ្ចឹមដោយសេរីមិនចោទលើបញ្ហាប្រើប្រាស់ចំណីផ្សំដូចមាន់ចិញ្ចឹមដាក់ទ្រុងនោះទេពីព្រោះវាដឹងថាវាត្រូវការបំពេញនូវអ្វីដែលខ្លួនវាខ្វះខាតដូចជា ជីវជាតិ ខនិជ ។ល។ ដូច្នេះចំណីជាអាហារដ៏មានសារៈសំខាន់ក្នុងការធ្វើឱ្យមាន់ឆាប់ធំធាត់លូតលាស់ល្អ និងផ្តល់ពងបានច្រើន. ដូច្នេះត្រូវផ្តល់ចំណីអាហារដែលមានជាតិប្រូតេអ៊ីន (សាច់) ថាមពលជាតិខ្លាញ់. វីតាមីន និងជាតិខនិជ ឱ្យបានសមស្រប។

- **ចំណីច្នៃផ្សំដែលមាននៅក្នុងតំបន់តាមរូបមន្ត**

| ល.រ | សមាសធាតុចំណី | បរិមាណ (5) |
|---|---|---|
| ១ | ស្រូវ. កញ្ចុំង. ពោតក្រហម. គ្រាប់ធញ្ញជាតិ | ៤០ -៥០ |
| ២ | កន្ទក់ | ១៥ |
| ៣ | ត្រីហាល ឬត្រីស្រស់ | ១០ |
| ៤ | ម្សៅកាកដូងស្ងួត | ១៥ |
| ៥ | សណ្តែកសៀង ឬសណ្តែកបាយ | ៦ |
| ៦ | ស្លឹកកន្ធំថេតស្ងួត | ៥ |
| ៧ | ម្សៅសំបកខ្យង | ២ |
| ៨ | អំបិល | 0.៥ |

## ៦. វិធានការការពារជំងឺ

- **វិធានការទូទៅ:** ការធ្វើអនាម័យទ្រុង និងផ្គត់ផ្គង់ចំនីទឹកស្អាតឱ្យបានគ្រប់គ្រាន់គឺជាវិធានការដ៏សមស្របបំផុតដែលកសិករម្ចាស់សត្វចាំបាច់ត្រូវតែអនុវត្តឱ្យបាន។ កុំនាំចូល រឺ ហូបមាន់ដែលសង្ស័យថាមានជំងឺ។
- **វិធានការដោយផ្ទាល់:** វិធានការចំបងការពារជំងឺឆ្លងគឺចាំបាច់ត្រូវចាក់ថ្នាំការពារអោយបានទៀងទាត់។ ខាងក្រោមនេះគឺជាថ្នាំការពារជំងឺមាន់ដែលគួរប្រើប្រាស់នៅប្រទេសកម្ពុជាយើង:

| ឈ្មោះវ៉ាក់សាំង | អាយុមាន់ | វិធីប្រើ | កំរិត/ ក្បាល |
|---|---|---|---|
| ញូវកាស F | ១ - ៧ ថ្ងៃ | ច្រមុះ. ភ្នែក | ១ - ២ ដំណក់ |
| ញូវកាស M | ២១ ថ្ងៃ | អោយផឹក | ១ - ២ ដំណក់ |
| ញូវក ាស M អុតមាន់ | ៣ ខែ ៧ថ្ងៃទៅ | ក្រោមស្បែក លើស្លាបរង | ១ សេសេ ១ ដង |
| អាសន្នរោគមាន់ រលាកបំពងខ្យល់ | ១ ខែទៅ ២១ថ្ងៃ | សាច់ដុំទ្រូង អោយផឹក | ១សេសេ ១ -២តំណក់ |

